## ប្រភេទនៃនាម ( the kinds of nouns )

នាមគឺជាពាក្យដែលគេប្រើជាឈ្មោះរបស់មនុស្ស ទីកន្លែង ឬវត្ថុ។

ចូរពិនិត្យមើលឃ្លាខាងក្រោមៈ

*Asoka* was a wise *king.*

នាម Asoka គឺនិយាយសំដៅទៅរកស្តេចពិសេសណាមួយ ប៉ុន្តែនាម king ប្រហែលជានិយាយសំដៅទៅរកស្តេចណាក៏ដោយព្រមទាំងជាប់ទាក់ទងទៅ Asoka ផងដែរ។ យើងហៅ Asoka នេះ ថា proper noun អសាធារណៈនាម ហើយយើងហៅ king ថាជា common noun សាធារណៈនាម។

### និយមន័យ

common noun គឺជាឈ្មោះដែលគេផ្តល់ឲ្យជាទូទៅ ចំពោះមនុស្សគ្រប់រូប ចំពោះវត្ថុទាំងឡាយដែលមានប្រភេទដូចគ្នា។

proper noun គឺជាឈ្មោះរបស់បុគ្គលឬទីកន្លែងពិសេសណាមួយ។

collective noun (សមូហនាម) គឺជាឈ្មោះមនុស្សឬវត្ថុដែលគិតបញ្ចូលគ្នានិងនិយាយជារួមជារបស់ឬមនុស្សតែមួយ។ ឧទាហរណ៍ៈ crowd, team, army, family...ect

abstract noun (អរូបិយនាម) គឺជាឈ្មោះនៃគុណភាព អំពើ ឬសភាព ដែលគេចាត់ទុកដាច់ដោយឡែកពីវត្ថុដែលជារបស់វា។ ឧទាហរណ៍ goodness, darkness, movement, boyhood, youth ...etc.

គេអាចចែកនាមទៅតាមប្រភេទ countable នាមរាប់បាន និង uncountable នាមរាប់មិនបាន។

countable nounនាមអាចរាប់បាន គឺជាឈ្មោះនៃមនុស្សឬវត្ថុ ។ល។ ដែលយើងអាចរាប់បាន ឧទាហរណ៍ សៀវភៅ ប៊ិច ផ្លែប៉ោម កូនក្មេង គ្រូពេទ្យ សេះ ។ល។

uncountable noun នាមមិនអាចរាប់បាន គឺជាឈ្មោះនៃវត្ថុដែលមិនអាចរាប់បាន។ ឧទាហរណ៍ milk, oil, sugar, gold, honesty។ uncountable noun បង្ហាញពីវត្ថុអរូបិយ និងសារធាតុ។

countable noun មានទម្រង់ពហុវចន ចំណែក uncountable noun មិនមានទម្រង់ពហុវចនទេ។

ឧទាហរណ៍ យើងនិយាយថា books តែយើងមិននិយាយថា milks ទេ។

## លំហាត់អនុវត្តន៍

តើពាក្យណាខ្លះជានាមក្នុងឃ្លាខាងក្រោម ហើយវាជា common noun, proper noun, collective noun ឬ abstract noun ។

1. The crowd was very big.
2. Always speaks the truth.
3. We all love honesty.
4. Our class consists of twenty people.
5. The elephant has great strength.
6. Solomon was famous for his wisdom.
7. Cleanliness is next to godliness.
8. We saw a fleet of ship in the harbor.
9. The class is studying grammar.
10. The Godavari over flowers its banks every year.
11. A committee of five was appointed.
12. Jawaharlal Nehru was the first Prime Minister of India.
13. The soldiers were rewarded for their bravery.
14. Without health there is no happiness.
15. He gave me a bunch of grapes.
16. I recognized your voice at once.
17. Our team is better than theirs.
18. Never tell a lie.
19. Wisdom is better than strength.
20. He sets a high value on his time.
21. I believe in his innocence.
22. This room is thirty feet in length.
23. I often think of the happy days of my childhood.
24. The streets of some of our cities are noted on their crookedness.
25. What is your verdict, gentlemen of the jury.

ចូរសរសេរ collective nouns ដែលគេប្រើសម្រាប់ពិពណ៌នាអំពី (1) cattle (2) soldiers និង (3) sailors ។

ចូរសរសេរលក្ខណៈសម្បត្តិរបស់ក្មេងប្រុសដែល (1) Lazy, (2) Cruel, (3) Brave, និង (4) Foolish ។

ចូរបង្កើត abstract noun ចេញពី adjectives ខាងក្រោម

Long, Young, Humble, Decent, Cruel, Bitter, Strong, True, Short, Prudent, Dark, Deep.

ចូរបង្កើត abstract noun ចេញពី verbs ខាងក្រោម

Laugh, Obey, Live, Except, Know, Steal, Believe, Serve, Hate, Please, Act, Starve.

ចូរបង្កើត abstract noun ចេញពី common noun ខាងក្រោម

King, Man, Thief, Woman, Bankrupt, Infant, Owner, Rogue, Author, Mother, Agent, Hero.

*Point out the Nouns in the following sentences, and say whether they are Common, Proper, Collective or Abstract, --*

ចូរចង្អុលឃ្លាខាងក្រោមនេះហើយនិយាយថាតើវាជាCommon noun, វាជាProper noun, វាជាCollective noun, ឬជាAbstract noun: --

1. The crowd (Collective Noun) was very big. ហ្វូងមនុស្សគឺច្រើន/ធំណាស់។

2. Always speak the truth (Abstract Noun) . ចូរអ្នកនិយាយការពិតជានិច្ច/គ្រប់ពេលវេលា។

3. We all love honesty (Abstract Noun) . ពួកយើងទាំងអស់គ្នាស្រលាញ់ភាពស្មោះត្រង់។

4. Our class (Common Noun) consists of twenty people. ថ្នាក់រៀនរបស់យើងមានសិស្ស២០នាក់។

   Class = ថ្នាក់/នៅក្នុងថ្នាក់

   To consist of = មាន(សមាសភាព)

5. The elephant (Common Noun) has great strength (Abstract Noun) . ដំរីជាសត្វមានកម្លាំងអស្ចារ្យ។

6. Solomon (Proper Noun) was famous for his wisdom (Abstract Noun) . Solomonល្បីល្បាញដោយសារភាពឈ្លាសវៃរបស់គាត់។

   Famous (adj) = ល្បីឈ្មោះ

   Famous for sth = ល្បីឈ្មោះដោយសារអ្វី១

7. Cleanliness (Abstract Noun) is next to godliness (Abstract Noun) . ភាពស្អាតគឺនៅជិតនិងភាពស្អាតស្អំ។

   Wise (adj) = ដែលមានគតិបណ្ឌិត, ដែលឈ្លាសវៃ

   Wisdom (n) = គតិបណ្ឌិត, ភាពឈ្លាសវៃ

   Cleanliness (n) = ភាពស្អាត

   Godliness (n) = ភាពល្អ, ភាពស្អាតស្អំ

   Next to = ក្បែរ/នៅជិតទៅនិង

8. We saw a fleet (Collective Noun) of ships (Common Noun) in the harbour (Common Noun) .

យើងបានឃើញនាវាមួយកងនៅក្នុងផែ។

   A fleet of = មួយកង(ឧ. អំពីនាវា, យន្តហោះ,....)

   Harbour (n) = ផែ

9. The class (Collective N) is studying grammar (Common N) .

   The class = សិស្សនៅក្នុងថ្នាក់/សិស្សទាំងអស់ក្នុងថ្នាក់

   Collective Noun + Singular Verb

eg. *The crowd* was very big.

*The class* is studying grammar.

10. The Godavari (Proper N) over flowers its banks (Common N) every year (Common N) .

ទន្លេGodavari ជន់លិចច្រាំងរៀងរាល់ឆ្នាំ។

   Let go to the river bank.

   River bank = ច្រាំងទន្លេឬបឹង

   A river overflows its banks. ទឹកស្ទឹងជន់លិចច្រាំង។

   The Mekong (Proper N) overflows its banks.

salarean.com

11. A committee (Collective N) of five was appointed.

គណកម្មាធិការដែលមានសមាជិក៥នាក់ត្រូវបានគេតែងតាំង។

A committee *of five* = គណកម្មាធិការដែលមានសមាជិក៥នាក់

A city *of 5 millions* = ទីក្រុងដែលមានប្រជាជនរស់នៅ៥លាននាក់

A village *of 500 families* = ភូមិដែលមានប្រជាជន៥០០គ្រួសារ

to appoint (vt) = តែងតាំង

12. Jawaharlal Nehru (Proper Noun) was the first Prime (Common N) Minister of India (Proper N).

Jawaahrlal Nehru គឺជានាយករដ្ឋមន្ត្រីដំបូងគេបង្អស់នៃប្រទេសឥណ្ឌា។

13. The soldiers (Common N) were rewarded for their bravery (Abstract N).

ពលទាហានទាំងអស់នេះត្រូវបានគេផ្តល់រង្វាន់ឲ្យដោយសារតែភាពអង់អាចក្លាហានរបស់ខ្លួន។

Reward (n) = រង្វាន់

To reward (vt) = ផ្តល់រង្វាន់

To reward sb for (doing) sth = ផ្តល់រង្វាន់ឲ្យsbដែលបានធ្វើអ្វី១

Sb is rewarded for doing sth. (Passive) = Sbត្រូវគេផ្តល់រង្វាន់ឲ្យដោយសារបានធ្វើអ្វី១

14. Without health there is no hapiness (Abstract N).

បើគ្មានសុខភាពល្អទេនោះក៏គ្មានសុភមង្គលដែរ។

Happiness = សុភមង្គល

15. He gave me a a bunch of (Collective N) grapes (Common N).

គាត់បានឲ្យខ្ញុំនូវទំពាំងបាយជូមួយចង្កោម។

A bunch of = មួយបាច់/មួយចង្កោម/មួយក្រុម/មួយកង/មួយហ្វូង

A bunch of flowers = ផ្កាមួយបាច់

16. I recognized your voice (Abstract N) at once.

ខ្ញុំអាចចំណាំ/ស្គាល់សំលេងអ្នកបានភ្លាម។

To recognize = ស្គាល់/ចំណាំបាន

At once (adv) = ភ្លាម

17. Our team (Collective N) is better than theirs.

ក្រុមបាល់ទាត់របស់យើងគឺល្អជាងរបស់ក្រុមបាល់ទាត់របស់ពួកគេ។

Possessive Pronoun (=សព្វនាមប្រាប់កម្មសិទ្ធិ): mine, your, his, their, his, her, ours.

18. Never tell a lie (Abstract N).    ចូរកុំនិយាយកុហក។

To tell a lie = to lie = និយាយកុហក

To lie to sb = និយាយកុហកsb

To lie about sth = និយាយកុហកអំពីsth

*Negative Imperative*:

eg. Do not tell a lie. / Never tell a lie. } = កុំនិយាយកុហកឲ្យសោះណា។(Neverសង្កត់ន័យខ្លាំងជាង)

Tell a lie = និយាយកុហកគេទៅ(ណា)

Always tell a lie = កុហកគេរហូតទៅកុំខានឲ្យសោះ(ណា)

salarean.com

19. $\underbrace{\text{Wisdom}}_{\text{Abstract N}}$ is better than $\underbrace{\text{strength}}_{\text{Abstract N}}$.

ភាពឈ្លាសវៃវាប្រសើរជាងកំលាំង។

20. He sets a high $\underbrace{\text{value}}_{\text{Abstract N}}$ on his time.

គាត់កំណត់តំលៃខ្ពស់ល់ពេលវេលារបស់គាត់។

21. I believe in his $\underbrace{\text{innocence}}_{\text{Abstract N}}$.

ខ្ញុំជឿជាក់លើភាពស្លូតត្រង់របស់គាត់។(ខ្ញុំជឿថាគាត់ជាមនុស្សគ្មានកំហុស)

To believe in sth = ជឿជាក់លើ

Innocence (adj) = ដែលស្លូតត្រង់/ដែលគ្មានទោសកំហុស

Innocence (n) = ភាពស្លូតត្រង់, ភាពគ្មានទោសកំហុស

22. This $\underbrace{\text{room}}_{\text{Common N}}$ is thirty feet in $\underbrace{\text{length}}_{\text{Abstract N}}$.

បន្ទប់នេះមានប្រវែង/បណ្តោយ 20 feet ។

Foot (n) = 40.38 cm > plural : feet

Long (adj) = វែង

Length (n) = ប្រវែង

6 metres in length = មានបណ្តោយ៦ម

The room is 6 metres | $\underbrace{\text{long.}}_{\text{ADJ}}$
| $\underbrace{\text{in}}_{\text{Prep}}$ $\underbrace{\text{length.}}_{\text{N}}$

បន្ទប់ហ្នឹងមានប្រវែង/បណ្តោយ ៦ម។

23. I often think of the happy $\underbrace{\text{days}}_{\text{Common N}}$ of $\underbrace{\text{childhood}}_{\text{Abstract N}}$.

ខ្ញុំតែងតែនឹងគិតទៅដល់សម័យកាលដ៏សប្បាយរីករាយនៅវ័យកុមារ។

Happy days = សម័យកាលដ៏សប្បាយរីករាយ

Days = សម័យកាល

24. The $\underbrace{\text{streets}}_{\text{Common N}}$ of some of our $\underbrace{\text{cities}}_{\text{Common N}}$ are noted for their $\underbrace{\text{crookedness}}_{\text{Abstract N}}$.

ផ្លូវថ្នល់នានា(ក្នុងចំណោម)នៃទីក្រុងមួយចំនួនក្នុងចំណោមទីក្រុងនានារបស់យើង។

Famous (adj)
Noted (adj) | for sth = ល្បីឈ្មោះដោយសារអ្វី១
Well-known (adj)

Crooked (adj) = ដែលទុច្ចរិត

Crookedness (n) = ភាពទុច្ចរិត

25. What is your $\underbrace{\text{verdict}}_{\text{Common N}}$, gentlemen of the $\underbrace{\text{jury}}_{\text{Collective N}}$ ?

តុលាការជាទីគោរព តើសាលក្រមរបស់លោកគឺជាអ្វីដែរ/យ៉ាងម៉េចដែរ?

Verdict (n) = (អំពីតុលាការ)សាលក្រម/មតិយោបល់

Jury (n) = ក្រុមប្រឹក្សាតុលាការ, អង្គចៅក្រម

salarean.com

ចូរសរសេរCollective Nounsដែលគេប្រើដើម្បីពិពណ៌នាអំពី

(1) Cattle; (2) Soldiers; (3) Sailors

| NOUN | COLLECTIVE NOUN |
|---|---|
| Cattle = គោក្របី | Herd = ហ្វូងគោក្របី |
| Soldiers = ទាហាន | Army = កងទ័ព |
| Sailor = នាវិក | Crew = ក្រុមនាវិក |

ចូរសរសេរអំពីលក្ខណៈសម្បត្តិដែលជារបស់ក្មេងប្រុងដែល

(1) Lazy; (2) Cruel; (3) Brave; (4) Foolish។

| ADJECTIVE | NOUNS |
|---|---|
| Lazy = ខ្ជិល | Laziness |
| Cruel = កាចសាហាវ, ឃោឃៅ | Cruelty = ភាពឬអំពើឃោឃៅ |
| Brave = ក្លាហាន | Bravery = ភាពអង់អាចក្លាហាន |
| Foolish = ឆ្កួត, ដែលឆ្កួតៗភ្លីៗ | Foolishness = អំពើឆ្កួតៗភ្លីៗ |

*Form Abstract Nouns from the following Adjectives:--*

| ADJECTIVE | NOUNS |
|---|---|
| Long = វែង | Length |
| Young = ក្មេង | Youth = យុវវ័យ |
| Humble = ដែលដាក់ខ្លួន/សាមញ្ញ | Humility = ការដាក់ខ្លួន |
| Decent = សមរម្យ | Decency = ភាពសមរម្យ/សុភាវធម៌ |
| Cruel = កាចសាហាវ | Cruelty = អំពីឃោឃៅ/យង់ឃ្នង |
| Bitter = ជូរចត់, ល្វីង | Bitterness = ភាពល្វីងជូរចត់ |
| Strong = ខ្លាំង | Strength = កំលាំង |
| True = ពិត | Truth = ការពិត/សច្ចធម៌ |
| Short = ខ្លី | Shortness = ភាពខ្លី |
| Prudent = ដែលប្រយ័ត្នប្រយែង | Prudence = ភាពប្រយ័ត្នប្រយែង |
| Dark = ខ្មៅ, ងងឹត | Darkness = ភាពងងឹត |
| Deep = ជ្រៅ | Depth = ជំរៅ |

*Form Abstract Nouns from the following Verbs:--*

| VERBS | ABSTRACT NOUNS |
|---|---|
| Laugh (vi) = សើច | Laughter = សំណើច |
| Obey (vt) = គោរពតាម, បង្គាប់ | Obedience = ការស្តាប់បង្គាប់ |
| Live (vt) = រស់នៅ | Life (n) = ជីវិត |
| Except (vi) = ពូកែឬជំនាញ(ខាង) | Excellence = ភាពអស្ចារ្យ, ភាពល្អប្រសើរបំផុត |
| Know (vt) = ចេះ, ដឹង | Knowledge = ចំណេះដឹង |
| Steal (vt) = លួច | Stealth = ការលួចលាក់ |
| To do sth with stealth = ធ្វើអ្វី១ដោយលួចលាក់ឬដោយស្ងាត់ៗ | |
| Believe (vt) = ជឿ | Belief = ជំនឿ |
| Serve (vt) = បម្រើ | Service = ការបំរើ, សេវា |

salarean.com

| | |
|---|---|
| Hate (vt) = ស្អប់ | Hatred = ការស្អប់, ការចងកំហឹង |
| Please (vt) = ធ្វើឲ្យរីករាយ, ផ្គាប់ចិត្ត | Pleasure = ការសប្បាយរីករាយ |
| Act (vi) = ធ្វើអំពើ, សកម្មភាព | Action = សកម្មភាពទង្វើ, អំពើ |
| Starve (vt) = បង្អត់អាហារ/(vi) = អត់អាហារ | Starvation = ការអត់អាហារ |
| Occupy (vt) = កាន់កាប់ | Occupation = ការកាន់កាប់ |

*Form Abstract Nouns from the following Common Nouns:--*

| COMMON NOUNS | ABSTRACT NOUNS |
|---|---|
| King | Kinghood = ភាពឬឋានៈស្ដេច |
| Man | Manhood = ភាពជាបុរស |
| Thief = ចោរ | Theft = ចោរកម្ម |
| Woman | Womanhood = ភាពជាស្ត្រី |
| Bankrupt = ក្ស័យធន<br>to go bankrupt / to meet bankrupt = ក្ស័យធន | Bankruptcy = ការក្ស័យធន |
| Infant = ទារក | Infancy = ទារកភាព/វ័យទារក |
| Owner = ម្ចាស់ | Ownership = កម្មសិទ្ធិ |
| Rogue = ទុច្ចរិត | Roguery = ភាពទុច្ចរិត, អំពើទុច្ចរិត |
| Author = អ្នកនិពន្ធ | Authorship = ការនិពន្ធ |
| Mother | Motherhood = ភាពឬឋានៈជាម្ដាយ |
| Agent = ភ្នាក់ងារ | Agency = ទីភ្នាក់ងារ |
| Hero = វីរៈជន | Heroism = វីរៈភាព |

salarean.com